**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងរដ្ឋប្បវេណីលេខ ១៣១
ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២
សាលក្រមលេខ ០១២ ស.រ.ណ/២២
ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្តាល

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០២២ ដោយមានសមាសភាពចូលរួមៈ

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

**ដើមចោទឈ្មោះ** [redacted]**រីណា** ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ននៅ[redacted] មានលោកមេធាវី [redacted] លោកមេធាវី [redacted] **ឌីម៉ង់** និង លោកមេធាវី[redacted] ជាអ្នកតំណាងដោយអាណត្តិ ។

ចុងចម្លើយឈ្មោះ[redacted]សុជាតិ ភេទស្រី អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ន [redacted] ។

**ខ្លឹមសារសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

១. សុំផ្តាច់សមគ្គសង្វាស់ (លែងលះ) ពីចុងចម្លើយឈ្មោះ[redacted]សុជាតិ ។
២. កូនឈ្មោះ[redacted]**សិរីរ័ត្ន** ភេទស្រី អាយុ ១០ឆ្នាំ និង កូនឈ្មោះ[redacted] **សិរីវិជ្ជា** ភេទប្រុស អាយុ ០៧ឆ្នាំ ភាគីដើមចោទឯកភាពឱ្យចុងចម្លើយជាអ្នកមានសិទ្ធិគ្រប់គ្រង មានអំណាចមេបា ។
៣. ទ្រព្យសម្បត្តិរួម ដីទំហំ ១៨៣ម$^{២}$ មានប័ណ្ណសម្គាល់សិទ្ធិអចលវត្ថុលេខ ០៨១០១៦០៥-០៣១៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨ មានទីតាំងស្ថិតនៅភូមិវត្តកណ្តាល ឃុំទឹកវិល ស្រុកស្អាង ខេត្តកណ្តាល ភាគីដើមចោទឯកភាពប្រគល់ឱ្យចុងចម្លើយមានសិទ្ធិគ្រប់គ្រងដើម្បីទុកជាការចិញ្ចឹមបីបាច់ថែរក្សាកូនៗទាំងពីរនាក់ខាងលើរហូតពេញវ័យនីតិភាព ។
៤. ឡានម៉ាកតូយ៉ូតាកូរ៉ូឡា សេរីឆ្នាំ១៩៩៩ ស្លាកលេខ ភ្នំពេញ 2K-4027 លេខម៉ាស៊ីន 1ZZ 5017452 លេខតួ INXBRIZE9X261963 ភាគីដើមចោទសុំសិទ្ធិគ្រប់គ្រង ។
៥. ភាគីដើមចោទឯកភាពបង់អាហារកាតព្វកិច្ចចំពោះកូនទាំងពីរតាមលទ្ធភាព ។
៦. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។



Scanned with CamScanner

## អង្គហេតុ និង ចំណុចវិវាទ

១. ពន្យល់ត្រួសៗអំពីរឿងក្តី

ដើមចោទ និង ចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍តាំងពីឆ្នាំ២០១១ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់លេខ ៤២ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ។ ក្រោយមកដើមចោទ និង ចុងចម្លើយរស់នៅមិនចុះសម្រុងគ្នា សាច់ញាតិក្រុមគ្រួសារមើលងាយ និង មិនផ្តល់តម្លៃឱ្យដើមចោទជាប្តី ជឿទៅលើឪពុកម្តាយខាងចុងចម្លើយជាងប្តី រកាំរកូសទាស់សម្តីគ្នាជាញឹកញាប់ ដែលបណ្តាលឱ្យដើមចោទអស់មនោសញ្ចេតនានឹងគ្នាជាប្តីប្រពន្ធតទៅទៀត ដូច្នេះទើបដើមចោទសម្រេចចិត្តដាក់ពាក្យបណ្តឹងលែងលះពីចុងចម្លើយឈ្មោះ [redacted] **សុជាតិ** តាមផ្លូវច្បាប់ ។

**២. ចំណុចវិវាទ៖**

- តើការអះអាងរបស់ដើមចោទជាការពិតឬទេ ?
- តើភាគីខាងដើមចោទ ឬ ចុងចម្លើយ ដែលគប្បីមានអំណាចមេបាលើកូនជាអនីតិជនទើបមានផលប្រយោជន៍ដល់កូនជាអនីតិជន ?
- តើទ្រព្យសម្បត្តិដែលសុំឱ្យបែងចែក ជាទ្រព្យរួម ឬទ្រព្យដោយឡែក ?

**៣. ការអះអាងរបស់ដើមចោទ និង សេចក្តីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ**

លោកមេធាវី [redacted] លោកមេធាវី [redacted] លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ សុំរក្សាខ្លឹមសារដូចក្នុងពាក្យបណ្តឹង ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ និង សេចក្តីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមលើកទី១ ទុកជាបានការដដែល ។ មេធាវីរបស់ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍បន្ថែមទៀតថាកូនក្តីខ្ញុំបាទ និង ចុងចម្លើយបានបញ្ជាក់ច្បាស់លាស់អំពីមូលហេតុដែលមិនអាចរួមរស់ជាមួយគ្នាបាន និង សុំឱ្យតុលាការសម្រេចតាមការទាមទាររបស់កូនក្តីខ្ញុំបាទ ។

ដើមចោទឈ្មោះ [redacted] **វីណា** បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្ញុំទទួលស្គាល់សេចក្តីថ្លែងការណ៍របស់មេធាវីទាំង ៣នាក់ ។ ចំពោះកូនឱ្យនៅជាមួយម្តាយបានរៀនសូត្របានត្រឹមត្រូវជាងនៅជាមួយខ្ញុំបាទ ។

**៤. ចុងចម្លើយ ៖** អវត្តមាន ។

**៥. ភស្តុតាងមានដូចជា**

- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០២២ ចេញពីសំបុត្រអាពាហ៍ពិពាហ៍លេខ ៤២ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១១ សៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១១ រវាងឈ្មោះ [redacted] **វីណា** និង ឈ្មោះ [redacted] **សុជាតិ** ។ (ច្បាប់ដើម)
- សេចក្តីចម្លងសំបុត្រកំណើត ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ ចេញពីសំបុត្រកំណើតលេខ ២៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២ សៀវភៅកំណើតលេខ ០១/២០១២ មានឈ្មោះ [redacted] **សិរីរ័ត្ន** ភេទស្រី កើតថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១២ ។ (ច្បាប់ដើម)
- សេចក្តីចម្លងសំបុត្រកំណើត ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ ចេញពីសំបុត្រកំណើតលេខ ៨៣ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ សៀវភៅកំណើតលេខ ០២/២០១៥ មានឈ្មោះ [redacted] **សិរីវឌ្ឍ** ភេទប្រុស កើតថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ ។ (ច្បាប់ដើម)



Scanned with CamScanner

- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១០១៦០៥-០៣១៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨ មានទីតាំងនៅភូមិវត្តកណ្តាល ឃុំទឹកវិល ស្រុកស្អាង ខេត្តកណ្តាល ។ (ថតចម្លង)
- លិខិតលក់រថយន្ត ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ រវាងឈ្មោះ [redacted] លាក់ និង ឈ្មោះ [redacted] រីណា ។ (ថតចម្លង)

## សំអាងហេតុ

១. យោងតាមសំបុត្រអាពាហ៍ពិពាហ៍លេខ ៤២ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ មានសៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១១ អាចបញ្ជាក់បានថា ដើមចោទឈ្មោះ [redacted] **រីណា** និង ចុងចម្លើយឈ្មោះ [redacted] **សុជាតិ** ជាសហព័ទ្ធនឹងគ្នាត្រឹមត្រូវតាមច្បាប់ ។ ប៉ុន្តែក្នុងការរស់នៅជាមួយគ្នារវាងដើមចោទ និង ចុងចម្លើយ រស់នៅមិនចុះសម្រុងគ្នា ដែលនាំឱ្យអស់មនោសញ្ចេតនា និង មិនអាចផ្សះផ្សាបាន ។ ដូចនេះតុលាការ យល់ឃើញថា មានមូលហេតុនៃការលែងលះ ស្របតាមបញ្ញត្តិមាត្រា **៩៧៨** កថាខណ្ឌទី១ ចំណុច **ង** នៃក្រមរដ្ឋប្បវេណី ។

២. ដើមចោទ បានអះអាងថា កូនជាអនីតិជនទាំងពីរនាក់ ឈ្មោះ [redacted] **សិរីរត្ន** និង ឈ្មោះ [redacted] **សិរីវិជ្ជា** រស់នៅជាមួយចុងចម្លើយទើបអាចបានរៀនសូត្របានត្រឹមត្រូវជាងនៅជាមួយដើមចោទ ។ ដូចនេះ តុលាការគប្បីសម្រេចឱ្យចុងចម្លើយជាអ្នកមានអំណាចមេបាលើកូនជាអនីតិជនទាំង ០២ នាក់ ដើម្បីផលប្រយោជន៍របស់កូននោះ ស្របតាមបញ្ញត្តិមាត្រា **១០៣៧** នៃក្រមរដ្ឋប្បវេណី ។

៣. ដើមចោទសុំសិទ្ធិគ្រប់គ្រងរថយន្តម៉ាក តូយ៉ូតាកូរ៉ូឡា ឆ្នាំ១៩៩៩ ស្លាកលេខ ភ្នំពេញ 2K-4027 ។ ប៉ុន្តែយោងតាមលិខិតលក់រថយន្តចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៩ ឃើញថា រថយន្តម៉ាក តូយ៉ូតាកូរ៉ូឡា ឆ្នាំ១៩៩៩ ស្លាកលេខ ភ្នំពេញ 2K-4027 ជាទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ ។ ដូចនេះ តុលាការគប្បីសម្រេចបែងចែកជាពីរចំណែកស្មើគ្នា ស្របតាមបញ្ញត្តិមាត្រា **៩៨០** នៃក្រមរដ្ឋប្បវេណី ។

៤. ត្រង់ចំណុចទី៣ និង ចំណុចទី៥ នៃខ្លឹមសារសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ មិនមានផលប្រយោជន៍នៃបណ្តឹង ស្របតាមបញ្ញត្តិមាត្រា **៧៤** នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ដូចនេះ តុលាការគប្បីមិនពិចារណាចំណុចនេះទេ ហើយគប្បីច្រានចោលការទាមទារនេះ ។

៥. ត្រង់ចំណុចទី៦ នៃខ្លឹមសារសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ដើមចោទបានទាមទារបង់ប្រាក់ប្រដាប់ក្តី ។ ដូចនេះ តុលាការនឹងសម្រេចតាមការទាមទារ ។

## សេចក្តីសម្រេចបញ្ចប់

១. ឱ្យដើមចោទឈ្មោះ [redacted] **រីណា** និង ចុងចម្លើយឈ្មោះ [redacted] **សុជាតិ** លែងលះគ្នា ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ ៤២ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១១ មានសៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១១ ។

២. ឱ្យចុងចម្លើយឈ្មោះ [redacted] **សុជាតិ** ជាអ្នកមានអំណាចមេបាលើកូនជាអនីតិជន ឈ្មោះ [redacted] **សិរីរត្ន** ភេទស្រី កើតថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១២ និង ឈ្មោះ [redacted] **សិរីវិជ្ជា** ភេទប្រុស កើតថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ ។



Scanned with CamScanner

៣. បែងចែកទ្រព្យរួម រថយន្តម៉ាក តូយ៉ូតាក្លូរ៉ូឡា ឆ្នាំ១៩៩៩ ស្លាកលេខ ភ្នំពេញ 2K-4027 ជាពីរចំណែកស្មើគ្នា មួយចំណែក ៥០% ឱ្យទៅដើមចោទ និង មួយចំណែក ៥០% ទៀតឱ្យទៅចុងចម្លើយ ។

៤. ច្រានចោលការទាមទារចំណុចទី៣ និង ទី៥ នៃខ្លឹមសារសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ។

៥. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះប្រកាសជាសាធារណៈ ។ ភាគីមានសិទ្ធិប្ដឹងឧទ្ធរណ៍នឹងសាលក្រមតាមការកំណត់ច្បាប់ ។

ថ្ងៃអង្គារ ២រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
កណ្ដាល, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២
**ចៅក្រម**
ហត្ថលេខា និង ត្រា [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ២រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
កណ្ដាល, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២

បានឃើញ
**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]